ជូនចំពោះ មាតាបិតារបស់សិស្សថ្នាក់ទី៨បច្ចុប្បន្ន ទាំងអស់៖

បើសិនជាលោកអ្នកបានចូលរួមក្នុងវិធីជ្រើសរើសសាលាកាលពីសរទរដូវកន្លងទៅនេះ (ឧទាហរណ៍៖ ជ្រើសរើសវិទ្យាល័យដែលលោកអ្នកចង់ឲ្យកូនទៅរៀន) សូមយកចិត្តទុកដាក់ចំពោះអ្វីៗដូចតទៅ៖

**ឆ្នាំនេះគេនឹងមិនផ្ញើ លិខិតជូនដំណឹងពីការជ្រើសរើសសាលា តាមប៉ុស្តិ៍សំបុត្រអាមេរិកាំងទេ! សូមកុំរង់ចាំលិខិតនេះតាមប៉ុស្តិ៍សំបុត្រៗ សូមកុំរង់ចាំឲ្យហួសពេលវេលាដែលគេកំណត់៖**

<u>**ពីថ្ងៃទី៥ ដល់ ទី១២ ខែមីនា ឆ្នាំ២០១៥**</u>

ចំពោះសិស្សានុសិស្សថ្នាក់ទី៨បច្ចុប្បន្ន ដែលបច្ចុប្បន្ននេះរៀននៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា **លិខិតជូនដំណឹងពីការជ្រើសរើសសាលានេះ នឹងមាននៅក្នុង** ***ទំព័រវិបសៃរបស់សិស្ស*** **និង** ***ទំព័រវិបសៃសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ*** *(Student Portal and Parent & Family Portal)* **នៅ ឬ មុន ម៉ោង ៦**:០០ ល្ងាច ថ្ងៃព្រហស្បតិ៍ ទី ៥ ខែមីនា ឆ្នាំ២០១៥។ (<u>សូមចុចត្រង់នេះ</u>) **អ្នកផ្តល់ឱវាទរបស់ក្រសួងអប់រំក៏អាចប្រើ លិខិតជូនដំណឹងពីការជ្រើសរើសសាលា របស់សិស្សានុសិស្សបានដែរ នៅពេលនោះ។ សូមអញ្ជើញទៅកាន់សាលារបស់កូនលោកអ្នករវាង <u>ថ្ងៃទី៥ និង ទី១២ ខែមីនា ឆ្នាំ២០១៥</u> ហើយសុំឲ្យអ្នកផ្តល់ឱវាទនៅសាលាជួយលោកអ្នកយកលិខិតជូនដំណឹងនេះ។**

ចំពោះសិស្សានុសិស្សថ្នាក់ទី៨បច្ចុប្បន្ន ដែលបច្ចុប្បន្ននេះមិនរៀននៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ហើយបានដាក់ពាក្យសុំចូលរៀននៅឆ្នាំសិក្សា ២០១៥-២០១៦ គេនឹងផ្ញើលិខិតជូនដំណឹងទៅអ្នកតាមអ៊ីមែល **ឲ្យទាន់ ម៉ោង ៦**:០០ ល្ងាច ថ្ងៃព្រហស្បតិ៍ ទី៥ ខែមីនា ឆ្នាំ២០១៥។ គេនឹងផ្ញើលិខិតជូនដំណឹងនេះទៅអ៊ីមែលដែលអ្នកបានផ្តល់ឲ្យ នៅពេលដាក់ពាក្យស្នើសុំដំបូង។

ការសម្រេចពីការជ្រើសរើសសាលាទាំងអស់ ត្រូវតែ ផ្តល់ ឬ ប្រគល់ ឲ្យក្រសួងអប់រំវិញ ឲ្យទាន់ ម៉ោង ៦:០០ ល្ងាច ថ្ងៃព្រហស្បតិ៍ ទី១២ ខែមីនា ឆ្នាំ២០១៥។ បើសិនជាក្រសួងអប់រំមិនទទួលការសម្រេចសម្រាប់សិស្ស ទាន់ ម៉ោង ៦:០០ ល្ងាច នៅថ្ងៃព្រហស្បតិ៍ ទី១២ ខែមីនា ឆ្នាំ២០១៥ ទេ ការអនុម័តលើការជ្រើសរើសសាលារបស់សិស្ស នឹងត្រូវបាត់បង់។

សូមចែកជូនព័ត៌មាននេះដល់សិស្សថ្នាក់ទី៨ដទៃទៀត ដែលនិយាយភាសាខ្មែរ។